# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៥៣

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះ រាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

## ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ **គ** ដូចមានចែងក្នុងមាត្រា៥ នៃ

ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ប្រមូលផ្តុំមន្ត្រីដែលមានទេពកោសល្យបច្ចេកទេស ឬការយល់ដឹងក្នុងការអនុវត្តជាក់ស្តែង សំរាប់ប្រតិបត្តិការងារជំនាញផ្សេងៗ នៅក្នុងអង្គភាពបច្ចេកទេសជំនាញ នៅថ្នាក់កណ្តាល និង ខេត្ត ក្រុង និង គ្រឹះស្ថានសាធារណៈរបស់ក្រសួង ស្ថាប័ន ។

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម មានឧបនិស្ស័យអាចបំពេញមុខតំណែងត្រួតពិនិត្យលើការងាររបស់មន្ត្រីក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេសផងដែរ ។

**មាត្រា ៣.-**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ស្ថាប័នសាមីនីមួយៗ និង ក្រោមការគ្រប់គ្រងរួមរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម មាន ៣ ឋានន្តរស័ក្តិៈ

- ឋានន្តរស័ក្តិទី១ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី២ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី៣ ឬ ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសបឋម មាន ១៤ ថ្នាក់ ។

## ជំពូកទី ២

## ការជ្រើសរើស

**មាត្រា ៥.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត និងជាមន្ត្រីរាជការ ។

ចំនួនមុខតំណែងជ្រើសរើសតាមជំនាញ និងតាមក្រសួង ស្ថាប័ន ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដោយយោងតាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

**មាត្រា ៦.-**

ការប្រលងជ្រើសរើសក្នុងចំណោមសិស្ស និស្សិត ត្រូវបើកចំហចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រលង និងយ៉ាងទាបមានសញ្ញាប័ត្រមធ្យមសិក្សាភាគទី២ ឬសញ្ញាប័ត្រសមមូល ។

លក្ខខណ្ឌក្នុងការប្រលងចូលក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋមសំរាប់បេក្ខជនជាមន្ត្រីរាជការ ត្រូវកំណត់យ៉ាងទាបត្រឹមថ្នាក់លេខ ១១ នៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស ឬមានសញ្ញាប័ត្រដូចកំណត់ខាងលើ ។

## ជំពូកទី ៣

## កម្មសិក្សាសាកល្បង ការតាំងស៊ប់ និងការតែងតាំង

**មាត្រា ៧.-**

បេក្ខជនដែលប្រលងជាប់ ត្រូវបែងចែកអោយទៅបំរើការនៅតាមអង្គភាពបច្ចេកទេសជំនាញនៅខេត្ត ក្រុង និង ថ្នាក់កណ្តាលរបស់ក្រសួង ស្ថាប័នសាមី ទៅតាមជំនាញដែលជ្រើសរើសក្នុងពេលប្រលងចូល ហើយត្រូវតែងតាំង

ជាមន្ត្រីបច្ចេកទេសបឋមកម្មសិក្សា ដោយប្រកាសរបស់ប្រធានស្ថាប័នទទួលបន្ទុក។

**មាត្រា ៨.-**

មន្ត្រីបច្ចេកទេសបឋមដែលជ្រើសរើសចេញពីសិស្សនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល១២ ខែ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតែងតាំងស៊ប់ក្នុងថ្នាក់លេខ១៤ នៃឋានន្តរស័ក្តិទី៣ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ដោយមានទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

**មាត្រា ៩.-**

មន្ត្រីបច្ចេកទេសបឋម ដែលធ្វើកម្មសិក្សាធ្លាក់ក្នុងពេលបំរើការងារ ត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅឆ្នាំទី២ ទៀត។ ក្នុងករណីធ្លាក់នៅឆ្នាំទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីសិស្ស និស្សិត ត្រូវលុបឈ្មោះចេញ។

**មាត្រា ១០.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីបច្ចេកទេសបឋម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដែលមានកំណត់ក្នុងមាត្រា ២ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចមានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

**មាត្រា ១១.-**

មន្ត្រីបច្ចេកទេសបឋម អាចត្រូវដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែង ដើម្បីទៅបំរើការនៅក្រសួង ស្ថាប័ន ឬអង្គភាពណាមួយផ្សេង តាមតំរូវការ និងតាមការយល់ព្រមពីសាមីខ្លួន។

## ជំពូកទី ៤

## ការដំឡើងថ្នាក់ និងដំឡើងឋានន្តរស័ក្តិ

**មាត្រា ១២.-**

មន្ត្រីបច្ចេកទេសបឋម ត្រូវបានដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

លក្ខណសម្បត្តិជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់ មានដូចខាងក្រោម៖

- វិន័យ និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវក្នុងការងារ និងមនសិការវិជ្ជាជីវៈ
- សាមគ្គីធមិ និងសីលធមិរស់នៅល្អ។

ការដំឡើងថ្នាក់នៃមន្ត្រីរាជការ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព។

ការដំឡើងថ្នាក់ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា ១៣.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់មន្ត្រីសាមី។

ចំនួនមុខតំណែងក្នុងឋានន្តរស័ក្តិនីមួយៗត្រូវកំណត់ដូចខាងក្រោម ៖

- ៥% ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី១
- ២៥% ជាអតិបរមាសំរាប់ឋានន្តរស័ក្តិទី២
- ៧០% ឡើងទៅ សំរាប់ឋានន្តរស័ក្តិទី៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី២ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិទី៣។

អាចដំឡើងទៅក្នុងឋានន្តរស័ក្តិទី១ គឺមន្ត្រីដែលបានឡើងដល់ថ្នាក់ទី ៧ នៃឋានន្តរស័ក្តិទី២។

ការដំឡើងឋានន្តរស័ក្តិ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

**មាត្រា ១៤.-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃសន្ទស្សន៍ ត្រូវកំណត់ស្របតាមមាត្រា ៣ និងមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ។

## ជំពូកទី ៥

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥-**

មន្ត្រីបច្ចេកទេសបឋមត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៥៥ ឆ្នាំ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា ១៦ .-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ត្រូវកសាងចេញពីការធ្វើសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ តាមជំនាញផ្សេងៗ នៅតាមអង្គភាពបច្ចេកទេសជំនាញថ្នាក់កណ្តាល និងខេត្តក្រុងរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៨.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ១៩.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

ពរល.០២.០៦.០០១៦៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៤០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ឈាងី តាន់**